# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១. **ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។

២. **ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

៣. **ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣៥រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន២៩រូប សរុបចំនួន៦៤រូប។

៤. **របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី "សេចក្តីព្រាងរបាយការណ៍នៃការអនុវត្តសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២៤" ដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. **សកម្មភាព និងលទ្ធផល ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារ និងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារ ក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក ដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជា បានធ្លាក់ចុះជាបន្ត។ **ឯកឧត្តមបណ្ឌិត** បានបើកនូវ "កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៥ ឆ្នាំ២០២៥"។ **ឯកឧត្តមបណ្ឌិត** បានលើកនូវអភិក្រមនៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍

និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ គោលនយោបាយជាតិនេះ មានឆន្ទៈយកប្រជាពលរដ្ឋជាគោល។

**លោកវេជ្ជបណ្ឌិត ទេព ណាវុធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ បានបង្ហាញពី សេចក្តីព្រាងរបាយការណ៍នៃការអនុវត្តសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២៤ ដោយបានបង្ហាញអំពី៖

១- បច្ចុប្បន្នភាព នៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា

២- ស្ថានភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៥

៣- បញ្ហាប្រឈម

៤- ទិសដៅបន្ត

៥- ផ្សេងៗ

ជាលទ្ធផលកិច្ចប្រជុំបានសម្រេច

- ឯកឧត្តមបានស្នើសុំទៅក្រសួងស្ថាប័នដែលមិនទាន់បានផ្តល់របាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំអេដស៍ សូមផ្តល់របាយការណ៍ឱ្យបានត្រឹមថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៥។
- អង្គការ AUA បានស្នើសុំប័ណ្ណមូលនិធិសមធម៌ សម្រាប់ពិនិត្យសុខភាពដល់ស្ត្រីបម្រើសេវាកម្សាន្តទេសចរណ៍ និងក្រុមប្រឈមមុខ ដើម្បីងាយស្រួលជាងការដែលពួកគាត់កើតជំងឺហើយទើបព្យាបាល វាបណ្តាលឱ្យខាតបង់ច្រើន។
- អគ្គលេខាធិការដ្ឋានគាំពារសង្គមឯកភាព ពិនិត្យ និងរកដំណោះស្រាយបញ្ជាក់ទៅនឹងសំណើរខាងអង្គការ AUA ព្រមទាំងរៀបចំស្លាយដាក់បញ្ចូលក្នុងរបាយការណ៍វឌ្ឍនភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- កាកបាទក្រហមកម្ពុជានឹងរៀបចំស្លាយដាក់បញ្ចូលក្នុងរបាយការណ៍វឌ្ឍនភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- នៅខែបន្ទាប់ស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចែករំលែកនូវសារាចរអន្តរក្រសួងស្តីពីការគ្រប់គ្រងការបាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។

ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានរំលឹកឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨ ដែលមានចក្ខុវិស័យ៖ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ និងគ្មានការមាក់ងាយ រើសអើង និងមានបេសកកម្ម ធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្នដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន់ និងមានចីរភាព ដោយ

មានគោលដៅ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាពដែលធានាថា ជំងឺអេដស៍លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពីឆ្នាំ២០២៨។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១១ព្រឹក ថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥

បានពិនិត្យត្រឹមត្រូវ

អ្នកធ្វើរបាយការណ៍

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ

ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

ស៊ុំ ផល្លា

វេជ្ជ. ហួត សេរីវង្ស

**បណ្ឌិត ឈឹម យិនដារ៉េត**